00145318

ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
The Office of the Co-Investigating Judges of the ECCC
Le Bureau des Co-Juges d'Instruction des CETC
លេខ/No: A35
ថ្ងៃទី (On/Le) 01 ខែ (Month/Mois) 10 ឆ្នាំ (Year/Année) 2007
ម៉ោងចូល (Time/Heure): 11:00 am

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានពន្ធនាគារ
មន្ទីរឃុំឃាំងអង្គជំនុំជម្រះវិសាមញ្ញ
លេខ: 25/07 មឃសក

ធ្វើនៅថ្ងៃទី 01 ខែ 10 ឆ្នាំ ២០០៧

Declassified to Public
06 September 2012

## របាយការណ៍ពិសេស

## ប្រធានមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សូមគោរពជូន

## លោក យូ ប៊ុនឡេង និងលោក Marcel Lemonde

## សហចៅក្រមស៊ើបអង្កេត

**កម្មវត្ថុ:** ស្តីពីលោកមេធាវី **ការ សាវុត្ថ** បំពានលើមុខវិជ្ជាជីវៈរបស់ខ្លួន។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន លោកសហចៅក្រម មេត្តាជ្រាប ថា: នៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០០៧ វេលាម៉ោង ១៥:១២ នាទី លោកមេធាវី **ការ សុវុត្ថ** បាននាំសហការីមក ជួបសួរកូនក្តីរបស់គាត់ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ជួបបានរយៈពេលជា ៣៨ នាទី ដល់ម៉ោង ៣:៤០ នាទី។ ក្រោយពីបញ្ចប់ជាមួយកូនក្តីរបស់ខ្លួន លោកមេធាវី **ការ សាវុត្ថ** បានឆ្លៀតឱកាសជួប លោក **នួន ជា** ដែលមិនមែនជាកូនក្តីរបស់ខ្លួននៅកន្លែងមើលទូរទស្សន៍ ភ្លាមនោះ មន្ត្រីរបស់ខ្ញុំបាទ បានមករាយការណ៍ជូនខ្ញុំបាទ ហើយខ្ញុំបាទក៏បានទៅដល់ទីនោះ ពេលដែលលោកមេធាវី ឃើញខ្ញុំបាទភ្លាម គាត់ក៏បញ្ឈប់ការសួររបស់គាត់។ ពួកគាត់ជួប និយាយគ្នាអស់រយៈពេល ៥ នាទី មិនដឹងនិយាយពីអ្វីទេ? សកម្មភាពល្មើសនេះ ខុសពីមុខជំនាញវិជ្ជាជីវៈជាមេធាវីការពារជនត្រូវចោទ។

00145319

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកសហចៅក្រមស៊ើបអង្កេត មេត្តាជ្រាប និងចាត់វិធានការ ដល់មេធាវីរូបនេះ តាមការគួរ។

សូម លោកសហចៅក្រមស៊ើបអង្កេត មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំបាទ។

ប្រធានមន្ទីរឃុំឃាំង

គីម ជួន

*ចំលងជូន:*

- អគ្គនាយកដ្ឋានពន្ធនាគារ
- គណៈកម្មការការពារអង្គជំនុំជម្រះ
- ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក
- ផ្នែកគ្រប់គ្រងតុលាការនៃ អ.វ.ត.ក
- អង្គភាពគាំពារការការពារក្ដី
- ឯកសារ កាលប្បវត្តិ